# របាយការណ៍សិក្ខាសាលា
## ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៣ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១ . ថ្ងៃ ខែ ឆ្នាំ ៖ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២

២. ទីកន្លែង ៖តាមប្រព័ន្ធអនឡាយ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការមួយចំនួនដែលពាក់ព័ន្ធសរុប៤៨រូប។

៤. របៀបវារៈ ៖

បច្ចុប្បន្នភាពកម្មវិធីជាតិសម្រាប់ការពារការចម្លងមេរោគអេដស៍ ពីមាតាទៅទារក ដែលធ្វើបទបង្ហាញដោយ លោកវេជ្ជបណ្ឌិត **ឈន សំណាង** ជំនួយការបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិ គាំពារមាតា និងទារក នៃក្រសួងសុខាភិបាល។

៥. លទ្ធផល ៖

៥.១ បានបង្ហាញពីវឌ្ឍនភាពនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ ពីម្តាយទៅកូន ក្នុងនោះមានគោលបំណង និងកម្មវិធីសេវាផ្សេងៗ ដែលបានអនុវត្តទៅលើក្រុមគោលដៅនិងសកម្មភាពសំខាន់ៗ ដែលសម្រេចបានកន្លងមក ទាក់ទងទៅនឹងបញ្ហាប្រឈម ក្នុងការលុបបំបាត់ការចម្លងពីម្តាយទៅកូន ចំពោះមេរោគអេដស៍ មេរោគស្វាយ និងជំងឺរលាកថ្លើមប្រភេទB គឺធ្វើយ៉ាងណា ដើម្បីឱ្យមេរោគអេដស៍ និងមេរោគស្វាយនៅតិចជាង ៥០ក្នុង១០០ ០០០កំណើត រស់នៅសម្រាប់ឆ្នាំ២០២៥ និងអត្រាប្រេវ៉ាឡង់នៃមេរោគរលាកថ្លើមត្រឹម០,១% នៅក្នុងឆ្នាំ២០៣០។ ដើម្បីឈានដល់គោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ តាមការកំណត់របស់មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកគឺ:

- គោលដៅ៩៥% បង្កើនការកំណត់អត្តសញ្ញាណមេរោគអេដស៍ និងមេរោគស្វាយ អំឡុងពេលស្ត្រីមានផ្ទៃពោះ និងដៃគូរបស់គាត់ធ្វើតេស្តរកមេរោគស្វាយ ត្រូវបានទទួលការថែទាំ និងព្យាបាល

- គោលដៅ៩០% ពង្រឹងការព្យាបាល និងតាមដាន
- គោលដៅ៧៥% វិធានការពង្រឹង ដើម្បីការពារ MTCT នៃជំងឺរលាកថ្លើមប្រភេទ B សម្រាប់មានផ្ទៃពោះដែលប្រឈមនឹងជំងឺ HBV MTCT នៅភ្នំពេញ
- គោលដៅ៨៥% ទារកនៅទូទាំងប្រទេសទទួលបានវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B
- ធ្វើឱ្យប្រសើរឡើងនូវព័ត៌មានយុទ្ធសាស្ត្រសម្រាប់ PMTC ទិន្នន័យ PMTCT មានគុណភាពគួរឱ្យទុកចិត្ត និងបំពេញតម្រូវការព័ត៌មានសម្រាប់សុពលភាពនៃMTCTទាក់ទងជាមួយមេរោគអេដស៍ និងមេរោគស្វាយ។
- ការពង្រឹងការគាំទ្រមន្ទីរពិសោធន៍ ដូចជាការធ្វើតេស្តរហ័សត្រូវបានរក្សាទុក និងប្រើប្រាស់ដោយអនុលោមតាមគោលការណ៍ណែនាំ និងឧបករណ៍វិភាគត្រូវបានថែទាំ និងក្រិតតាមខ្នាតត្រឹមត្រូវ។
- ធានាការគោរពសិទ្ធិមនុស្ស និងសមភាពយេនឌ័រ រាល់ការធ្វើតេស្តមេរោគអេដស៍ មេរោគស្វាយ និងHBV តាមការស្ម័គ្រចិត្ត ផ្តល់ការប្រឹក្សាមុន និងក្រោយការធ្វើតេស្ត សេវាកម្ម PMTCT ទាំងអស់ត្រូវបានផ្តល់ជូនក្នុងលក្ខខ័ណ្ឌរក្សាការសម្ងាត់ និងគួរឱ្យគោរព។
- ការព្យាបាលរោគស្វាយមាននៅក្នុងសេវាសម្ភព និងការបញ្ចូលមេរោគអេដស៍ត្រូវបានស្វែងរក និងប្រើប្រាស់ក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងវិធីសាស្ត្រ។

តាមរយៈសកម្មភាពដែលបានអនុវត្តយើងទទួលបានៈ

៥.២ អត្រាការចូលមកពិនិត្យផ្ទៃពោះរបស់ស្ត្រីមានផ្ទៃពោះយ៉ាងតិចមួយដងក្នុងមួយឆ្នាំ មានការធ្លាក់ចុះពី៩៨,២%នៅឆ្នាំ២០២០ មកនៅត្រឹម៨៤% នៅឆ្នាំ២០២១។

៥.៣ អត្រាស្ត្រីមានផ្ទៃពោះដែលដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ មានការធ្លាក់ចុះពី៩៨,២% នៅឆ្នាំ ២០២០ មកនៅត្រឹម៨៦,៣% នៅឆ្នាំ២០២១។

៥.៤ អត្រាស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគអេដស៍ ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ក្នុងអំឡុងពេលមានគភ៌ ដើម្បីកាត់បន្ថយហានិភ័យឆ្លងពីម្តាយទៅកូន មានការធ្លាក់ចុះពី៨៦%នៅឆ្នាំ ២០២០ មកនៅត្រឹម៧៩% នៅឆ្នាំ២០២១។

៥.៥ អត្រាទារកដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ ដែលបានទទួលការធ្វើ viroload test ក្នុងរយៈពេល២ខែនៃការចាប់កំណើត មានការធ្លាក់ចុះពី៩៨%នៅឆ្នាំ២០២០ មកនៅត្រឹម៥១.៦% នៅឆ្នាំ២០២១។

កត្តាដែលបណ្តាលឱ្យមានអត្រាធ្លាក់ចុះរវាងការប្រៀបធៀបពីឆ្នាំ២០២០ នឹង២០២១មកពីការរាតត្បាតជំងឺកូវីដ-១៩ មូលហេតុនេះអាចសន្និដ្ឋានបានថា គាត់មិនឱ្យមានផ្ទៃពោះ ឬក៏មិនហ៊ានមកពិនិត្យនៅមន្ទីរពេទ្យ។

៥.៦ អត្រាចម្លងពីម្ដាយទៅកូន រួមជាមួយអំឡុងពេលបំបៅដោះ មានការកើនឡើងពី១១,៨% នៅឆ្នាំ ២០២០ ទៅ១៣.៨% នៅឆ្នាំ២០២១។

៥.៧ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក កំពុងសិក្សារៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់ប្រមូលទិន្នន័យពីវិស័យឯកជន ទាក់ទងនឹងការចម្លងមេរោគអេដស៍ ពីម្ដាយទៅកូន។

៥.៨ កិច្ចប្រជុំបានសម្រេចរួមគ្នាទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការដៃគូ ជួយធ្វើការ ផ្សព្វផ្សាយការយល់ដឹងជំរុញឱ្យស្ត្រីមានផ្ទៃពោះទាំងអស់ ចូលមកទទួលសេវាពិនិត្យ និងពិគ្រោះយោបល់នៅមូលដ្ឋានសុខាភិបាល ដើម្បីការពារហានិភ័យនៃការចម្លងមេរោគអេដស៍ និងកាមរោគផ្សេងៗ (ស្វាយ) ទៅកូន។

៥.៩ សិក្សាពីឧបសគ្គ និងកំណត់នូវវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព និងទាន់ពេលដើម្បីកាត់បន្ថយផលប៉ះពាល់នៃមេរោគកូវីដ-១៩ និងផលប៉ះពាល់ផ្សេងៗទៀត ដើម្បីសម្រេចឱ្យបានគោលដៅ ៩៥ ៩៥ ៩៥ តាមការកំណត់របស់មជ្ឈមណ្ឌលជាតិ គាំពារមាតា និងទារក (NMCHC) ស្របទៅនឹងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣។

៦.ប្រជុំខែក្រោយកំណត់យកថ្ងៃច័ន្ទ ៩រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ។

ថ្ងៃច័ន្ទ ៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

**ប្រធានអង្គប្រជុំ**

**អ្នកធ្វើរបាយការណ៍**

គុំ ឆល្យ

**ឈឹម ឃិនដារ៉េត**